**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ៣២៣/០៦១/២០១៧

ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៧

**សេចក្តីសម្រេច**

លេខ : ១៦៤/០០៤/២០១៧ កបធ.ច

ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៧

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ០៣៩.រស ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៧ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មជំពូកទី១២ ថ្មី ប្រការ ៤៨ ថ្មី (បី) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី៣១ ខែ មករា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាវិសាមញ្ញ នីតិកាលទី៥ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះនៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៧ វេលាម៉ោង ១៦:០០ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភាបានអនុវត្តត្រឹមត្រូវតាមបទប្បញ្ញត្តិនៃមាត្រា ៨២ ថ្មី វាក្យខ័ណ្ឌទី៣ មាត្រា ៩៤ នៃរដ្ឋធម្មនុញ្ញ និង ប្រការ ៨២ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាក្នុងការពិនិត្យនិងអនុម័តសេចក្តីស្នើវិសោធនកម្មជំពូកទី ១២ ថ្មី ប្រការ ៤៨ ថ្មី (បី) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មជំពូកទី១២ ថ្មី ប្រការ ៤៨ ថ្មី (បី) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជានេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង ការអនុម័តវិសោធនកម្មជំពូកទី១២ ថ្មី ប្រការ ៤៨ ថ្មី (បី) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ខ្លឹមសារនៃជំពូកទី១២ ថ្មី (មួយ) ប្រការ ៤៨ ថ្មី (បួន) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ស្របនឹងរដ្ឋធម្មនុញ្ញ ។

## សម្រេច

**មាត្រា ១.** វិសោធនកម្មជំពូកទី១២ ថ្មី ប្រការ ៤៨ ថ្មី (បី) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាវិសាមញ្ញ នីតិកាលទី៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៧

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

**អ៊ឹម ឈុនលឹម**